ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ : ០៣ កយ.សសរ/២៤

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមស្រាវជ្រាវ និងវិភាគផ្នែកយុទ្ធសាស្ត្រ និងគោលនយោបាយ ក្នុងវិស័យយុត្តិធម៌

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១៣០ អនក្រ.បក ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងយុត្តិធម៌

## សម្រេច

**ប្រការ១ .-**

បង្កើត **ក្រុមស្រាវជ្រាវ និងវិភាគផ្នែកយុទ្ធសាស្ត្រ និងគោលនយោបាយក្នុងវិស័យយុត្តិធម៌ (ក.យ.ន.)** ដែលមានសមាសភាព ដូចខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តម **ខិន ម៉ាលីន** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ប្រធាន |
| ២-ឯកឧត្តម **កេង សុម៉ារិទ្ធ** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៣-ឯកឧត្តម **ញាន វណ្ណៈ** | រដ្ឋលេខាធិការ និងជានាយកខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | សមាជិក |
| ៤-ឯកឧត្តម **តាន់ហ៊ាង ជាវ័ណ្ណ** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ៥-ឯកឧត្តម **សេង ឌីណា** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ៦-លោកជំទាវ **សុខ ឆវ័ន្ត** | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |



មហាវិថីសម្តេចសុធារស ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322, 023 217 841, 023 212 693

៧-ឯកឧត្តម **ឡាយ លាងសេង** ទីប្រឹក្សា និងជានាយករងខុទ្ទកាល័យ
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជំនួយការស្រាវជ្រាវ

៨-លោកជំទាវ **ឈុន លីណាម៉ាតា** ទីប្រឹក្សាឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជំនួយការស្រាវជ្រាវ

៩-ឯកឧត្តម **ធិន ឧត្តរា** នាយករងខុទ្ទកាល័យ
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជំនួយការស្រាវជ្រាវ

១០-ឯកឧត្តម **ទីវ សុវណ្ណារតន៍** ទីប្រឹក្សា និងជានាយករងខុទ្ទកាល័យ
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជំនួយការស្រាវជ្រាវ

១១-លោក **ឆុន អរុណរ៉ា** សមាជិកខុទ្ទកាល័យ
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជំនួយការស្រាវជ្រាវ

១២-លោក **ម៉ែន មិស្សុតសារៈ** ជំនួយការឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជំនួយការស្រាវជ្រាវ។

**ប្រការ២ ..**

ក្រុមការងារពិសេសនេះ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- សិក្សាស្រាវជ្រាវ វិភាគ និងផ្តល់យោបល់ផ្នែកយុទ្ធសាស្ត្រ និងគោលនយោបាយ សម្រាប់ការងារពាក់ព័ន្ធនឹងការកែទម្រង់ក្នុងវិស័យយុត្តិធម៌
- ពិនិត្យ វិភាគ និងផ្តល់យោបល់លើការរៀបចំ ឬការធ្វើវិសោធនកម្មច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗក្នុងវិស័យយុត្តិធម៌
- តាមដាន និងវិភាគព័ត៌មានពាក់ព័ន្ធនឹងវិស័យច្បាប់ និងយុត្តិធម៌
- រៀបចំសុន្ទរកថា បទអន្តរាគមន៍ និងឯកសារជំនួយស្មារតីនានារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
- អនុវត្តភារកិច្ចផ្សេងទៀត តាមការប្រគល់របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**ប្រការ៣ ..**

អនុប្រធាន និងសមាជិកនៃក្រុមការងារពិសេសនេះ ត្រូវចូលរួមក្នុងកិច្ចប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន ឬមានធុរៈ អនុប្រធានអាចកោះប្រជុំ ឬដឹកនាំកិច្ចប្រជុំជំនួសបាន តាមការប្រគល់សិទ្ធិពីប្រធាន។

ប្រធានក្រុមការងារពិសេសនេះ មានសិទ្ធិអញ្ជើញថ្នាក់ដឹកនាំ និងមន្ត្រីជំនាញរបស់ក្រសួងយុត្តិធម៌ដែលមានការពាក់ព័ន្ធ ដើម្បីចូលរួមផ្តល់យោបល់ក្នុងកិច្ចប្រជុំ តាមការចាំបាច់។

**ប្រការ៤ ..**

ក្រុមការងារពិសេសនេះ ប្រើប្រាស់កញ្ចប់ថវិការបស់ក្រសួងយុត្តិធម៌ ដើម្បីអនុវត្តការងាររបស់ខ្លួន។

ប្រធាន អនុប្រធាន និងសមាជិកនៃក្រុមការងារពិសេសនេះ អាចទទួលបានប្រាក់រង្វាន់លើកទឹកចិត្តដោយផ្អែកលើសមិទ្ធកម្មការងារ តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**ប្រការ៥** ..

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋានកិច្ចការតុលាការ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងយុត្តិធម៌ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៩រោច ខែ មិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ មករា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ